ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤.សសរ

សេចក្ដីសម្រេច
ស្ដីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសម្របសម្រួល គម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែន ស្ទឹងបត់-បានណាងអៀង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតគណៈកម្មការសម្របសម្រួលគម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែន ស្ទឹងបត់-បានណាងអៀង ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ស៊ុន ចាន់ថុល**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន	ប្រធាន
២- ឯកឧត្តម **សុខុម គគចន្ទមុនី**	រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន

www.pheakdeylaw.com

៣- ឯកឧត្តម	**ហ៊ីង ថូរ៉ាក់ស៊ី**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤- ឯកឧត្តម	**ហ៊ាន សាហ៊ីប**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥- ឯកឧត្តម	**អ៊ុង ស៊ាន**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៦- ឯកឧត្តម	**ង៉ូ យិនស៊ីម**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៧- ឯកឧត្តម	**ម៉ក់ ពេជ្ររិទ្ធ**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល	សមាជិក
៨- ឯកឧត្តម	**លេង ទី**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៩- ឯកឧត្តម	**យិត បុណ្ណា**	អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១០- ឯកឧត្តម	**គី សុតាត់**	អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១១- ឯកឧត្តម	**គុណា ញឹម**	អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ	សមាជិក
១២- ឯកឧត្តម	**នូ វឌ្ឍនៈ**	អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១៣- ឯកឧត្តម	**សួន បវរ**	អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ	សមាជិក
១៤- លោក	**ឡាយ សៀងលី**	ប្រធាននាយកដ្ឋានបច្ចេកទេសនិងវាស់វែងនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន	សមាជិក។

ប្រការ២.-

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ដឹកនាំ និងតម្រង់ទិសនៃការអនុវត្តគម្រោង
- សហការ និងសម្របសម្រួលជាមួយភាគីថៃ ក្នុងដំណើរការនៃការអនុវត្តគម្រោង
- សហការ និងរៀបចំកិច្ចព្រមព្រៀងសាងសង់ផ្សេងៗដែលពាក់ព័ន្ធជាមួយភាគីថៃ
- រៀបចំគោលការណ៍គ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តគម្រោង
- ណែនាំ និងដោះស្រាយបញ្ហាផ្សេងៗដែលកើតឡើងនៅក្នុងពេលអនុវត្តគម្រោង
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រការ៣.-

ប្រធានគណៈកម្មការមានសិទ្ធិអញ្ជើញសមាជិកឱ្យចូលរួមប្រជុំ និងមានសិទ្ធិអញ្ជើញមន្ត្រីបច្ចេកទេសពាក់ព័ន្ធនៃក្រសួងសាធារណការ និងដឹកជញ្ជូន ឬលើកសំណើ ដើម្បីអញ្ជើញមន្ត្រីនៃក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីពិគ្រោះយោបល់តាមការចាំបាច់។

ប្រការ៤.-

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com